7

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

៣៣៣*៤៤

**តុលាការកំពូល**

សំណុំរឿងរដ្ឋប្បវេណី

លេខៈ ៨៤

ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០០

**សាលដីកា**

លេខៈ ១៣៤

ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០០៤

**នាមនាមប្រជារាស្ត្រខ្មែរ**

**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០០៤ ដោយមានសមាសភាពដូចតទៅ :

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ឃឹម** | **ប៊ុណ្ណា** | ជាប្រធានក្រុមប្រឹក្សាជំនុំជំរះ |
| ២-លោក | ស៊ិន | ឌឹម | ជាចៅក្រម |
| ៣-លោក | ជីវ | កេង | ជាចៅក្រម |
| ៤-លោក | ប្រាក់ | គីមសាន | ជាចៅក្រមរបាយការណ៍ |
| ៥-លោក | យស់ | សូខឿន | ជាចៅក្រម |
| ៦-លោក | ឈឹម | ស៊ីផល | ជាចៅក្រម |
| ៧-លោក | ប៉ែន | សារឿន | ជាចៅក្រម |
| ៨-លោក | សោម | សិរីវឌ្ឍ | ជាចៅក្រម |
| ៩-លោក | ម៉ុង | មុន្នីចរិយា | ជាចៅក្រម |

**ក្រឡាបញ្ជី**

កញ្ញា សេន សុខា

**តំណាងមហាអយ្យការ**

លោក ឈួន ចាន់ថា ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខលើកទី២ ពីសាលដីការដ្ឋប្បវេណីលេខ ៧៨៩ ចុះថ្ងៃទី ២៨ ខែតុលា ឆ្នាំ១៩៩៩ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ២១ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍រវាង :

ដើមចោទឈ្មោះ ទី ធុំ (ជាចុងបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៥២ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើចំការ ទីលំនៅភូមិទី៧ ឃុំខ្សាម ស្រុក-ខេត្តកំពង់ឆ្នាំង ។

ដើមចោទឈ្មោះ **ចាន់ អាត** (ជាចុងបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៥២ឆ្នាំ ជាតិខ្មែរ មុខរបរលក់ដូរ ទីលំនៅភូមិទី៧ ឃុំខ្សាម ស្រុក-ខេត្តកំពង់ឆ្នាំង ។

ដើមចោទឈ្មោះ **ឈួស ឡឿន** (ជាចុងបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៤៧ឆ្នាំ ជាតិខ្មែរ មុខរបរនគរបាលខេត្ត ទីលំនៅភូមិទី៧ ឃុំខ្សាម ស្រុក-ខេត្តកំពង់ឆ្នាំង ។

មានមេធាវី លោក ពេជ្រ វិសាល ។

ចុងចម្លើយឈ្មោះ **ហួត វ៉ាន់ហាន** (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទស្រី អាយុ៣៩ឆ្នាំ ជាតិខ្មែរ មុខរបរបុគ្គលិកមន្ទីរហិរញ្ញវត្ថុខេត្ត ទីលំនៅភូមិទី៧ ឃុំខ្សាម ស្រុក-ខេត្តកំពង់ឆ្នាំង ។

**<u>កម្មវត្ថុបណ្តឹង</u>** : ប្តឹងសុំសិទ្ធិកាន់កាប់ប្រើប្រាស់រោងម៉ាស៊ីនអារឈើ និង សំណង់ .

បានឃើញបណ្តឹងសាទុក្ខលើកទី២លេខ ៥៥៦ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៩ របស់ឈ្មោះ ហួត វ៉ាន់ហាន ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៧៨៩ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចសាលដីកាទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ៨៤ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០០ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី០៩-៧-១៩៩២ របស់ដើមចោទឈ្មោះទី ពុំ និង ចាន់ អាត បានអះអាងថា ខ្លួនបានបង្កើតរោងចក្រអារឈើមួយមានទីតាំងនៅភូមិទី៧ ឃុំខ្សាម ស្រុកកំពង់ឆ្នាំង ដោយដាក់ដើមទុនជាមាស១៧តម្លឹង ០៥ជី ចាប់ដំណើរការពីខែសីហា ឆ្នាំ១៩៨៩ លុះដំណើរការបាន១៥ខែ ដល់កំណត់សងលុយធនាគារ ប៉ុន្តែដោយលុយមិនគ្រប់ ខ្លួនក៏ខ្ចីពីឈ្មោះហួត វ៉ាន់ហាន ចំនួន ៨២០.០០០៛ ស្មើនឹងមាស០២តម្លឹង ០៧ជី ០.៤ហ៊ុន ដោយឯកភាព គិតអត្រាការប្រាក់៥% ក្នុងមួយខែ ប៉ុន្តែដល់កំណត់ខែកញ្ញា ឆ្នាំ១៩៩១ សងមិនគ្រប់ទេ អត្រាការប្រាក់នឹងឡើងដល់១០% ក្នុងមួយខែ ។ នៅថ្ងៃទី០១-០១-១៩៩១ ឈ្មោះហួត វ៉ាន់ហាន បានបំពានកិច្ចសន្យា ចូលមកកាន់កាប់រោងចក្រអារឈើ ដោយគំរាមកំហែង ធ្វើស្រេចតែចិត្ត គ្មានការអនុញ្ញាតពីខ្លួនទាំងពីរនាក់ទេ ថែមទាំងពុំដែលចេញថ្លៃឈ្នួលឱ្យខ្លួនទាំងពីរនាក់ឡើយ ។

ទន្ទឹមនឹងនោះក៏បានតម្លើងការប្រាក់ ១០% ទៀត សរុបទាំងដើម ទាំងការ ត្រូវជា៦តម្លឹង ០៣ជីមាសសន្លឹក ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ០៣ចុះថ្ងៃទី១៥ ខែមិនា ឆ្នាំ១៩៩៣ របស់តុលាការខេត្តកំពង់ឆ្នាំង ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងរបស់ដើមចោទចុះថ្ងៃទី០៩-៧-៩២ មានលក្ខណៈត្រឹមត្រូវ

តាមទំរង់ និងគតិច្បាប់ ។

២-បង្គាប់ឱ្យឈ្មោះទី ពុំ ១ ,ឈ្មោះចាន់ អាត ១ និងឈ្មោះសួស ជឿន "តតិយជន" ប្រគល់ប្រាក់ជំពាក់៨២ម៉ឺនរៀល និងការប្រាក់ចំនួន៩១.២៣០៛ ទៅឈ្មោះហួតវ៉ាន់ហាន

៣-បង្គាប់ឱ្យឈ្មោះហួត វ៉ាន់ហាន ផ្តល់ប្រាក់ថ្លៃឈ្នួលកម្មករអារឈើ១ ថ្លៃម៉ាស៊ីនអារ គិតចេញជាម៉ែត្រគីប ក្នុង១ថ្ងៃ២ ថ្លៃរោង និងទីតាំង ថ្លៃសំណឹកម៉ាស៊ីន សរុបរយៈពេល១៥ ខែ ចំនួន ១០.៨៧០.០០០៛ "ដប់លានប្រាំបីសែនប្រាំពីរម៉ឺនរៀលគត់ "និង ជម្ងឺចិត្តជាប្រាក់៧លានរៀល ទៅឱ្យឈ្មោះទី ពុំ ១,ឈ្មោះចាន់ អាត ១ ,ឈ្មោះសួស ជឿន ១ ចាប់ពីថ្ងៃប្រកាសសាលក្រម នេះតទៅ ការទាមទារលើសពីនេះបដិសេធចោល ។

៤-បង្គាប់ឱ្យឈ្មោះហួត វ៉ាន់ហាន ចេញផុតពីរង្វង់អាជីវកម្មម៉ាស៊ីនអារឈើចំណុចផ្លូវទី១ ភូមិខ្សាម សង្កាត់ទី៤ ទីរួមខេត្ត ខេត្តកំពង់ឆ្នាំង ហើយប្រគល់ទៅម្ចាស់ដើមវិញ ទាំងរោង ទាំងម៉ាស៊ីន ទាំងឧបករណ៍ពាក់ព័ន្ធនិងទីតាំងទំហំ ២.៩២៥ម៉ែត្រក្រឡា ចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

- ហាមផ្តាច់មិនឱ្យភាគីណាមួយទៅរុកគួន មានគំនិតទុច្ចរិត ឈ្លានីស តាមមហិច្ឆិតាលោភលន់ណាមួយឡើយ ។តាមមាត្រា ១០,១១,១២,១៩ ,៥៩ និង ៦០ នៃក្រិត្យច្បាប់លេខ៣៨ក្រច ចុះថ្ងៃទី២៨-១០-៨៨ ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា ។

- សាលក្រមនេះ ជំនុំជំរះជាសាធារណៈចំពោះមុខគូក្តី ។

- បើភាគីណាមួយមិនសុខចិត្ត អាចប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២២ ខែមិនា ឆ្នាំ១៩៩៣ របស់ឈ្មោះហួត វ៉ាន់ហាន ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ០៣ ចុះថ្ងៃទី ១៥ ខែមិនា ឆ្នាំ១៩៩៣ របស់តុលាការខេត្តកំពង់ឆ្នាំង ត្រង់ចំណុចសេចក្តីសំរេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ១៥០ស្ហន ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ១៩៩៥ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-សម្រេចទទួលពាក្យបណ្តឹងឧទ្ធរណ៍ឈ្មោះ ហួត វ៉ាន់ហាន ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ។

២-សំរេចលើកសាលក្រមតុលាការខេត្តកំពង់ឆ្នាំងលេខ ៣ ចុះថ្ងៃទី១៥ មិនា ១៩៩៣ ចោលដោយបង្វិលរឿងនេះទៅតុលាការសាមុី ដើម្បីចាត់ការតាមនីតិវិធីតុលាការ និងជំនុំជំរះតាមច្បាប់ ។

៣-សំរេចរឹបអូសប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ ១៣.០០០៛ គឺពន្ធចុះបញ្ជីក្តី

និង ពន្ធហ្លឹង ២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០៛ ចំណាយក្នុងកិច្ចប្រគល់ដីកាកោះ ១០.០០០៛ សរុប ១៣.០០០៛ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ៥២ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ១៩៩៥ របស់តុលាការខេត្តកំពង់ឆ្នាំង ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងរបស់ឈ្មោះទី ពុំ ,ចាន់ អាត, សួស ជឿន "ដើមចោទ" ចុះថ្ងៃទី០៩-៧-១៩៩២ ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-ទទួលពាក្យបណ្តឹងបន្ថែមរបស់ដើមចោទចុះថ្ងៃទី១២-៧-៩៥ ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

៣-សំរេចឱ្យឈ្មោះទី ពុំ,ចាន់ អាត,សួស ជឿន ,សងប្រាក់ជំពាក់៨២ម៉ឺនរៀល ទៅឱ្យឈ្មោះហួត វ៉ាន់ហន "ចុងចម្លើយ" ប៉ុន្តែអំពីការប្រាក់ ត្រូវសំរេចតាមអត្រាការប្រាក់៥ភាគរយក្នុងមួយឆ្នាំ គិតពីថ្ងៃទី០៩-៧-៩២ រហូតដល់ថ្ងៃសាលក្រមចូលជាស្ថាពរ ។ តាមក្រឹត្យច្បាប់លេខ ៣៨ក្រច ចុះថ្ងៃទី២៨-១០-៨៨ ។

៤-សំរេចឱ្យឈ្មោះ ហួត វ៉ាន់ហន ផ្តល់ប្រាក់ឈ្នួលកម្មករឈើមូល ថ្លៃសំណឹកម៉ាស៊ីន ថ្លៃឈ្នួលរោងដាក់ឈើ ,ថ្លៃឈ្នួលផ្ទះកម្មករនៅ , ថ្លៃឈ្នួលដីដាក់ឈើមូលសរុបរយៈពេល ៤៥ខែ គិតជាប្រាក់១០៣.០៥០.០០០៛ "មួយរយបីលានសូន្យសែនប្រាំម៉ឺនរៀល" ទៅឱ្យឈ្មោះទី ពុំ ចាន់ អាត, សួស ជឿន គិតពីថ្ងៃទី៩-៧-៩២ រហូតដល់ថ្ងៃអនុវត្តសាលក្រមចូលជាស្ថាពរ ។ សេចក្តីសំរេចក្រៅពីនេះ បដិសេធចោល ។

៥-សំរេចឱ្យឈ្មោះហួត វ៉ាន់ហន ព្រមទាំងញាតិលោហិត រុះរើទ្រព្យសម្បត្តិផ្ទាល់ខ្លួន ដែលការពាក់ព័ន្ធចេញផុតពីរង្វង់រោងម៉ាស៊ីនអារឈើទាំងមូល ដែលត្រូវប្រគល់ឱ្យឈ្មោះទី ពុំ,ចាន់ អាត,សួស ជឿន ក្នុងរយៈពេល៦០ថ្ងៃចាប់តាំងពីថ្ងៃដែលសាលក្រមនេះចូលជាស្ថាពរ។

៦-សំរេចឱ្យឈ្មោះទី ពុំ, ចាន់ អាត, សួស ជឿន ចូលគ្រប់គ្រងប្រើប្រាស់រោងម៉ាស៊ីនអារឈើទាំងមូលនៅផ្លូវលេខ១ ភូមិទី៧ ឃុំខ្សាម ស្រុកកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ជាកម្មសិទ្ធិស្របច្បាប់ ចាប់តាំងពីថ្ងៃដែលសាលក្រមនេះចូលជាស្ថាពរ ។

៧-សំរេចឱ្យចុងចម្លើយបង់ប្រាក់ប្រដាប់ក្តី ពន្ធចុះបញ្ជីក្តី ពន្ធហ្លឹង១.៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់២០០៛ រង្វាន់អ្នកប្រគល់ដីកាកោះ៥.០០០៛ សរុប ៧.០០០៛ ប្រាក់នេះត្រូវបានកាត់យកពីដើមចោទដែលបានបង់ទុករួចហើយ។ បើហួសឧទ្ធរណ៍ឱ្យចុងចម្លើយបង់ប្រាក់ប្រដាប់ក្តី៧.០០០៛ ទៅឱ្យដើមចោទវិញ និងបង់ពន្ធសមាមាត្រ $\frac{៣៨.២២០.០០០ \text{ គុណ } ១}{១០០}$ ស្មើ៣៨២.២០០៛ ឱ្យពន្ធសមាមាត្រ $\frac{៣៨២.២០០ \text{ គុណ } ៨០}{១០០}$ ស្មើ២៧៣៧៦០៛ បន្ថែមទៀតដែលត្រូវបង់ចូលថវិកា

រដ្ឋ និងជារង្វាន់ក្រឡាបញ្ជីក្នុងព្រះរាជាណាចក្រកម្ពុជា $\frac{៣៤២.២០០ \text{ គុណ } ២០}{១០០}$ ស្មើ៦៨៤៤០៛ ។ តាមមាត្រា ១០,១១,១២,១៩,៥៨ និង៦០ នៃក្រិត្យច្បាប់លេខ ៣៨ក្រច ចុះថ្ងៃទី២៨-១០-៨៨ ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា ។

សាលក្រមនេះជំនុំជំរះជាសាធារណៈចំពោះមុខគូក្តី បើភាគីណាមិនសុខចិត្តអាចប្តឹងឧទ្ធរណ៍ ២ខែ ចាប់តាំងពីថ្ងៃនេះតទៅ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ១២ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ១៩៩៥ របស់ឈ្មោះហួត វ៉ាន់ហាន ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ៥២ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ១៩៩៥ របស់តុលាការខេត្តកំពង់ឆ្នាំង ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៤៣៤ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ ៖

១-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៣-៨-៩៥ របស់ឈ្មោះហួត វ៉ាន់ហាន ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែអំពីគតិច្បាប់ ត្រូវលើកចោលខ្លះ ទុកខ្លះ ។

២-តម្កល់សាលក្រមលេខ ៥២ ចុះថ្ងៃទី២៣-០៨-៩៥ របស់តុលាការខេត្តកំពង់ឆ្នាំង ទុកជាបានការ លើកលែងតែចំណុចទី៤ នៃសាលក្រមនេះ ត្រូវលើកចោល ឯចំណុចទី៣ នៃសាលក្រមនេះ ត្រូវកែប្រែដូចតទៅ ៖

- សំរេចឱ្យឈ្មោះទី ពុំ, ចាន់ អាត, សួស ជឿន សងប្រាក់ចំនួន០៦តម្លឹង ០២ជី ០៥ហ៊ុន ០៧លី ទៅឈ្មោះហួត វ៉ាន់ហាន ។

៣-រឹបអូសប្រាក់ប្រដាប់ក្តី១៣.០០០៛ ដែលដើមបណ្តឹងឧទ្ធរណ៍បានបង់រួចហើយ គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្វ៊ឹង២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០៛ ចំណាយលើការប្រគល់ដីកាកោះ៥.០០០៛ និងអាជ្ញាធរតុលាការ ៥.០០០៛ ។

៤-សាលដីកានេះជំនុំជំរះនិងប្រកាសជាសាធារណៈ ចំពោះមុខគូក្តី ។ បើកផ្លូវប្តឹងសាទុក្ខ ក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ៣៧២ ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ១៩៩៧ របស់ឈ្មោះទី ពុំ ចាន់ អាត និងឈ្មោះ សួស ជឿន ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ៤៣៤ ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍លើសេចក្តីសំរេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៩៣ ចុះថ្ងៃទី១៨ ខែមិនា ឆ្នាំ១៩៩៩ របស់តុលាការកំពូល ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ ៖

១-ទទួលបណ្តឹងសាទុក្ខលេខ ៣៧២ ចុះថ្ងៃទី ០៦ ខែតុលា ឆ្នាំ១៩៩៧ របស់

លោកទី ពុំ, លោកចាន់ អាត និងលោក សួស ជឿន ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់។

២-ទុកជាមោឃៈចំណុចទី២ ត្រង់ឃ្លា លើកលែងតែចំណុចទី៤នៃសាលក្រមនេះ ត្រូវលើកចោល ឯចំណុចទី៣ នៃសាលក្រមនេះ ត្រូវកែប្រែដូចតទៅ : សំរេចឱ្យឈ្មោះទី ពុំ ,ចាន់ អាត,សួស ជឿន សងប្រាក់ចំនួន០៦តម្លឹង ០២ជី ៥ហ៊ុន ០៧លី ទៅឈ្មោះហួត វ៉ាន់ហាន នៃសាលដីការដ្ឋប្បវេណីលេខ ៤៣៤ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍ ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ៣៥៩ ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៩៧ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ត្រង់ចំណុចដែលត្រូវទុកជាមោឃៈខាងលើ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ១៩.០០០រ ដែលលោកទី ពុំ, ចាន់ អាត, និង សួស ជឿន បានបង់រួចហើយគឺ :

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្វើងចំនួន ៤.០០០រ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រ សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ .

-ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០រ សរុប១៩.០០០រ ហើយតម្រូវឱ្យលោកហួត វ៉ាន់ហាន សងប្រាក់ចំនួន១៩.០០០រនេះ ទៅដើមចោទវិញ ។

៥-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី ១៨ ខែ មិនា ឆ្នាំ១៩៩៩ ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៧៨៩ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលជំនុំជំរះជាសមត្ថកិច្ចនូវសំណុំរឿងនេះ តាមមាត្រា១១ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពសាលាជំរះក្តី ដោយសាលដីការបស់តុលាការកំពូល សំរេចបង្វិលអោយមកសាលាឧទ្ធរណ៍ជំនុំជំរះជាថ្មីឡើងវិញ ។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ៥២ ចុះថ្ងៃទី២៣-៨-៩៥ របស់តុលាការខេត្តកំពង់ឆ្នាំង ទុកជាបានការពេញទាំងមូល ។

៣-សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្តី សំរេចបើកផ្លូវសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលើកទី២លេខ ៩៥៦ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៩ របស់ឈ្មោះហួត វ៉ាន់ហាន ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៧៨៩ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចសាលដីកាទាំងមូល ។

បានឃើញសារណាការពារចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០០ របស់ឈ្មោះហួត វ៉ាន់ហាន។

បានឃើញសារណាឆ្លើយតប ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០០ របស់ឈ្មោះទី ពុំ ,ចាន់ អាត និង សួស ជឿន ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា : ក្នុងការសំរេចជាថ្មីឡើងវិញ សាលាឧទ្ធរណ៍បានគោរពតាមសាលដីកាទី១ របស់តុលាការកំពូល ដូច្នេះតុលាការកំពូលពុំអាចលើក រឿងនេះមកជំនុំជំរះរួមក្រុមលើអង្គហេតុនិងអង្គច្បាប់តាមមាត្រា២២៦ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ឡើយ ។ អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះសំរេចតាមច្បាប់ ។

បានស្តាប់ចំលើយរបស់ឈ្មោះ ហួត វ៉ាន់ហាន នាពេលជំនុំជំរះថា : ក្នុងឆ្នាំ១៩៨៧ រោងម៉ាស៊ីនបានបើកដំណើរការនៅទីរួមខេត្តកំពង់ឆ្នាំង បានសហការជាមួយឯកជន បើកសិប្បកម្ម រោងម៉ាស៊ីនអាឈើ ក្នុងដំណើរការអាជីវកម្មរោងម៉ាស៊ីននេះ ទីរួមខេត្តបានខ្ចីលុយពីធនាគារចំនួន ៨២០.០០០៛ ដោយធានានូវរោងម៉ាស៊ីនទាំងមូលដើម្បីទុនបង្វិល ។លុះឆ្នាំ១៩៩០ ក្រោយពីសមាជិក ភាគហ៊ុនបានដកចេញ និងប្រគល់រោងម៉ាស៊ីនឱ្យឈ្មោះទី ពុំ និង ចាន់ អាត រួមជាមួយទីរួមខេត្ត ដើម្បីគ្រប់គ្រងដោយរយៈពេលកំណត់ត្រូវសងធនាគារ ឈ្មោះទី ពុំ និងចាន់ អាត បានខ្ចីប្រាក់ខ្លួន ដោយបង្វែរការធានាកមបញ្ចាំខ្លួនវិញ ដោយបានធ្វើកិច្ចសន្យាជាលក្ខអក្សរ រួចទើបចាប់ផ្តើមរកស៊ី រកស៊ីជាមួយគ្នា ។ ក្រោយមកសំភារៈត្រូវប្រើប្រាស់ខ្វះខាត ហើយតម្រូវឱ្យការអាឈើឱ្យអតិថិជន មានច្រើន អ្នកទាំងពីរបានយល់ព្រមឱ្យទិញដើម្បីដំណើរការ ដោយរៀងរាល់ចុងខែម្តងធ្វើការទូទាត់ ដោយមានការកត់ត្រាទាំងសងខាង ។ បន្ទាប់មកអ្នកទាំងពីរបានដើររកស៊ីបាត់ ដោយបានផ្ទេររោង ម៉ាស៊ីនមកឱ្យខ្លួន ។ លុះឆ្នាំ១៩៩១ ឈ្មោះទី ពុំ និង ចាន់ អាត ពុំមានលទ្ធភាពដើម្បីរត់ច្បាប់ ក៏ប្រគល់ការងារឱ្យខ្លួន ដូច្នេះចាប់ពីថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៩១ មករោងម៉ាស៊ីនអាឈើបានកែ ប្រែពីរោងសិប្បកម្មទីរួមខេត្ត មកជារោងចក្រអាឈើរបស់ហួត វ៉ាន់ហាន វិញ ។ នៅថ្ងៃទី០២ ខែ កក្កដា ឆ្នាំ១៩៩១ ក្រោយពីទីរួមខេត្ត ឈ្មោះទី ពុំ និងចាន់ អាត បានសំរេចផ្ទេររោងចក្រអាឈើ មកឱ្យខ្លួន និងពុំមានលទ្ធភាពសងនូវចំនួនសាច់ប្រាក់ដែលខ្ចីខ្លួននោះ ក៏បានធ្វើកិច្ចសន្យាមួយប្រគល់ រោងម៉ាស៊ីនអាឈើទៅឱ្យប៊ុត សារ៉ុម និងខ្លួន ។ ឯឈ្មោះសួស ជឿន និងបក្សពួកបានយកសោរ ទៅចាក់មិនឱ្យរោងម៉ាស៊ីនដំណើរការ ។ សរុបសេចក្តីមកខ្លួនមិនឯកភាព បញ្ហាទីតាំង ព្រោះឃុំ ខេត្តបានប្រគល់ឱ្យខ្លួន អាចឱ្យខ្លួនទិញដីនេះទេ បញ្ហាឱ្យខ្លួនសងលុយ គឺមិនព្រម ឯកម្មករខ្លួនបាន បើកប្រាក់ខែឱ្យគ្រប់ហើយ ។

បានស្តាប់ចំលើយរបស់ឈ្មោះទី ពុំ នាពេលជំនុំជំរះថា : ចំពោះរឿងនេះ ខ្លួនពុំបានដឹងអ្វី

ទាំងអស់ ក្រដាសនោះខ្លួនមិនទទួលស្គាល់ទេ ហើយកម្មករមានពីរផ្នែក គាត់ចេញតែថ្លៃកម្មកររបស់គាត់ ឯកម្មករខ្លួនគាត់មិនបានបើកលុយឱ្យទេ ហើយកាលនោះខ្លួនល្ងិតល្ងង់មិនយល់ ក៏យល់ព្រម ។

បានស្តាប់ចំលើយរបស់ឈ្មោះចាន់ អាត នាពេលសវនាការថា : កាលដែលគេឱ្យខ្លួនផ្តិតមេដៃ គឺនៅលើក្រដាសនោះ គ្មានសរសេរអក្សរអ្វីទាំងអស់ គេបោកខ្លួនរហូត បានជាខ្លួនយល់ព្រមផ្តិត ហើយបានជាលុយកើន ព្រោះគេគិតសព្វមុខទាំងអស់ អ្វីដែលគាត់ធ្វើគឺធ្វើដើម្បីផលប្រយោជន៍របស់គាត់ ចំពោះក្រដាសនេះ ខ្លួនពុំទទួលស្គាល់ទេ ខ្លួនសុំទាមទារការខាតបង់ពេលវេលា បាត់បង់អាជីពជាច្រើនឆ្នាំ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ សួស ជឿន នាពេលសវនាការថា : ពួកខ្លួនបានរៃលុយគ្នាធ្វើអាជីវកម្មដោយបង់ឱ្យរដ្ឋជារៀងរាល់ខែ ។ លោកហួត វ៉ាន់ហាន បានកំណត់ឱ្យតែលោកទី ពុំ និងចាន់ អាត អាឈើ តែរបស់លោកប៉ុណ្ណោះ ។ ក្រោយមកម៉ាស៊ីនខូច លោកក៏បានទិញសំភារៈមកដាក់ ដោយក្នុង១ខែ ទូទាត់ម្តង ដោយពុំឱ្យលោកទី ពុំ និង ចាន់ អាត ដឹងទេ លុះធ្វើយូរៗទៅកម្មកររកបាយស៊ីផង ពេលនោះលោកក៏ឆ្លៀតឱកាសយកម៉ាស៊ីននេះចេញមុខ ដោយមិនបានសួរនាំអ្វីទាំងអស់ ។ របស់របរ ទី ពុំ និងចាន់ អាត មានសំភារៈចំនួន៣៦មុខ តែឥឡូវបានបាត់អស់ហើយ ហើយបងខ្លួនបានយកលុយខ្លួនទៅធ្វើរោងម៉ាស៊ីន តែខ្លួនមិនបានទៅចូលរួមទេ ដោយខ្លួនរវល់ទៅធ្វើការតាមខេត្ត លុះត្រឡប់មកវិញ ខ្លួនទារលុយចំណេញ គាត់ថាគ្មានលុយ ព្រោះហួត វ៉ាន់ហាន បានយកអស់ហើយ ខ្លួនឱ្យគាត់រត់ច្បាប់ មិនមែនប្រគល់រោងម៉ាស៊ីនឱ្យទេ ហើយចំពោះជុំវិញបញ្ហាលិខិតស្នាមនេះ ឈ្មោះទី ពុំ និងចាន់ អាត មិនបានដឹងរឿងអ្វីទាំងអស់ ដោយមិនបានទុកជាឯកសារឱ្យសាម៉ីខ្លួនទេ ស្រាប់តែពេលប្តឹងទើបគាត់បង្ហាញឯកសារត្រង់នេះ ហើយទើបពួកខ្លួនប្តឹងបដិសេធសំណុំរឿងរបស់តុលាការ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកពេជ្រ វិសាល ជាមេធាវីការពារឱ្យម្ចាស់បណ្តឹងសាទុក្ខបានលើកឡើងថា : នៅឆ្នាំ១៩៨៧ កូនក្តីខ្លួនបានបង្កើតរោងម៉ាស៊ីន លុះដល់ឆ្នាំ១៩៩០ កូនក្តីខ្លួនបានខ្ចីលុយលោក ហួត វ៉ាន់ហាន តែមិនបានផ្ទេរកម្មសិទ្ធិរោងម៉ាស៊ីនឱ្យទេ ។ ចំពោះអង្គច្បាប់វិញចំណុចទី២ របស់តុលាការកំពូល បានបដិសេធសាលដីកាសាលាឧទ្ធរណ៍ ហើយសាលាឧទ្ធរណ៍ ក៏បានកាត់សេចក្តីតាមអំណាចតុលាការកំពូលហើយ ហើយសាលាឧទ្ធរណ៍សំរេចតំកល់សាលក្រមរបស់តុលាការខេត្តកំពង់ឆ្នាំងដែរ ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយរបស់គូភាគី និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវី

ដើមចោទ ．

- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

**តុលាការកំពូល**

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៥៥៦ ចុះថ្ងៃទី២០-១២-១៩៩៩ របស់លោកហួត វ៉ាន់ ហាន ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបានតាមមាត្រា ១៤នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី និង តាមមាត្រា២២៦ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌដែលមានអានុភាពអនុវត្តក្នុងរឿងរដ្ឋប្បវេណីផងដែរ ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចតម្កល់សាលក្រមរដ្ឋប្បវេណីលេខ ៥២ ចុះថ្ងៃទី២៣-៨-១៩៩៥របស់តុលាការខេត្តកំពង់ឆ្នាំង ទុកជាបានការពេញទាំងមូលនោះ ជាការកំន្ត ច្រឡំ ពីព្រោះសាលក្រមនេះ ត្រូវបានសាលាឧទ្ធរណ៍និង តុលាការកំពូលតម្កល់ទុកជាបានការហើយ លើកលែងតែចំណុចទី២ ត្រង់ឃ្លា " លើកលែងតែចំណុចទី៤ នៃសាលក្រមនេះ ដែលត្រូវលើកចោល ឯចំណុចទី៣ នៃសាលក្រមនេះ ត្រូវកែប្រែដូចតទៅ : សំរេចឱ្យឈ្មោះទី ពុំ, ចាន់ អាត សួស ជឿន សងប្រាក់ចំនួន០៦តម្លឹង ០២ជី ០៥ហ៊ុន ០៧លី ទៅឈ្មោះហួត វ៉ាន់ហាន " ដែលតុលាការកំពូលបានទុកជាមោឃៈ និងបង្វិលឱ្យសាលាឧទ្ធរណ៍ជំនុំជំរះជាថ្មីឡើងវិញ ។ ដូច្នេះសាលាឧទ្ធរណ៍ពុំមានសមត្ថកិច្ចលើកយកសាលក្រមដែលចូលជាស្ថាពររួចហើយ មកសំរេចជាថ្មីម្តងទៀតទេ គឺត្រូវតែជំនុំជំរះលើចំណុច ដែលតុលាការកំពូលបង្វិលឱ្យជំនុំជំរះជាថ្មីឡើងវិញប៉ុណ្ណោះ ។

- យល់ឃើញថា តាមពាក្យបណ្តឹងសាទុក្ខ ចុះថ្ងៃទី១២-០៨-១៩៩៧ ដើមចោទបានប្តឹងសាទុក្ខត្រង់ចំណុចទី៤ ដែលសាលាឧទ្ធរណ៍បានលើកចោលពីសាលក្រមរបស់តុលាការខេត្តកំពង់ឆ្នាំងដែរ ប៉ុន្តែពេលដែលសាមីខ្លួនមកប្តឹងសាទុក្ខផ្ទាល់និងផ្តិតមេដៃលើសេចក្តីសុំប្តឹងសាទុក្ខលេខ៣៧២ ចុះថ្ងៃទី០៦-១០-១៩៩៧ដើមចោទប្តឹងសាទុក្ខតែលើត្រង់ចំណុចឱ្យខ្លួនសងទៅហួតវ៉ាន់ហាន ប៉ុណ្ណោះ ពុំបានប្តឹងសាទុក្ខត្រង់ចំណុចលើកលែងមិនឱ្យឈ្មោះហួត វ៉ាន់ហាន សងខ្លួនទេ ។ ដូច្នេះ តុលាការកំពូលគប្បីយកតាមចំណុចដែលចែងក្នុងសេចក្តីសុំប្តឹងសាទុក្ខផ្ទាល់ ។

- យល់ឃើញថា តាមកិច្ចសន្យាស្តីពីការផ្ទេរប្រគល់ឈ្មោះកាន់កាប់រោងម៉ាស៊ីនចុះថ្ងៃទី០១-០៣-១៩៩១ និងតាមលិខិតកិច្ចសន្យាចុះថ្ងៃទី០២-០៧-១៩៩១ ដើមចោទបានប្រគល់រោងម៉ាស៊ីនអារឈើនេះ ផ្តាច់ឱ្យទៅចុងចម្លើយជាកម្មសិទ្ធិហើយ ហើយពុំមានកិច្ចសន្យាណាថា ចុងចម្លើយបានជួលរោងម៉ាស៊ីននេះពីដើមចោទទេ ដូច្នេះចុងចម្លើយពុំមានជាប់កាតព្វកិច្ចអ្វីត្រូវសងទៅដើមចោទទេ ម្យ៉ាងទៀត ក៏ពុំមានភស្តុតាងណាថាចុងចម្លើយបានបំភ័ន្តដើមចោទឱ្យផ្តិតមេដៃលើកិច្ចសន្យាទាំងពីរ

ខាងលើនេះទេ ។

- យល់ឃើញថា សាលដីកាវិនិច្ឆ័យលេខ៨៣៤ចុះថ្ងៃទី១២-៨-១៩៩៧ របស់សាលាឧទ្ធរណ៍ដែលបានចូលជាស្ថាពរនោះ លោកហួត វ៉ាន់ហាន ពុំបានប្តឹងសាទុក្ខទេ ។ ដូច្នេះ តុលាការកំពូលពុំមានសមត្ថកិច្ចពិនិត្យអំពីដីទីតាំងរោងម៉ាស៊ីនអារឈើទេ ។

- យល់ឃើញថា តាមសាលដីកាវិនិច្ឆ័យលេខ ៨៣៤ ចុះថ្ងៃទី១២-៨-១៩៩៧ របស់សាលាឧទ្ធរណ៍ បានសំរេចលើកចំណុចទី៤ នៃសាលក្រមវិនិច្ឆ័យលេខ ៥២ ចុះថ្ងៃទី២៣-៨-១៩៩៥ របស់តុលាការខេត្តកំពង់ឆ្នាំងចោលហើយ ប៉ុន្តែដើមចោទពុំបានប្តឹងសាទុក្ខពីចំណុចនេះទេ។ ដើមចោទប្តឹងសាទុក្ខតែលើចំណុចសងប្រាក់៦តម្លឹង ០២ជី ០៥ហ៊ុន ០៧លី ឱ្យឈ្មោះហួត វ៉ាន់ហាន ប៉ុណ្ណោះ ។ ដូច្នេះ បណ្តឹងសាទុក្ខលើកទី២ របស់លោក ហួត វ៉ាន់ហាន នៅពេលនេះ តុលាការកំពូល មានសមត្ថកិច្ចជំនុំជំរះតែលើចំនួនទឹកប្រាក់ ដែលចុងចម្លើយត្រូវសងទៅដើមចោទប៉ុណ្ណោះ ចំណុចក្រៅពីនេះ តុលាការកំពូលពុំមានសមត្ថកិច្ចជំនុំជំរះទេ ។

-យល់ឃើញថា មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា ដើមចោទពិតជាបានខ្ចីប្រាក់ពីចុងចំលើយចំនួន៨២ម៉ឺនរៀលប្រាកដមែន ដូច្នេះ តុលាការកំពូល គប្បីសំរេចឱ្យដើមចោទសងទៅចុងចំលើយនូវប្រាក់ដើមនោះនិងការប្រាក់៥%ក្នុង១ឆ្នាំ គិតពីថ្ងៃទី០៩-៧-១៩៩២រហូតដល់ថ្ងៃសងគ្រប់។

- យល់ឃើញថា សាលដីកាវិនិច្ឆ័យលេខ ៧៨៩ ចុះថ្ងៃទី ២៨-១០-១៩៩៩ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានការខុសឆ្គងទាំងទំរង់ ទាំងគតិច្បាប់ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី ចំពោះមុខគូក្តី

១-ទទួលបណ្តឹងសាទុក្ខលេខ ៩៥៦ ចុះថ្ងៃទី២០-១២-១៩៩៩ របស់លោកហួត វ៉ាន់ហាន ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-ទុកជាមោឃៈសាលដីកាវិនិច្ឆ័យលេខ ៧៨៩ ចុះថ្ងៃទី ២៨-១០-១៩៩៩ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-សំរេចឱ្យលោកទី ពុំ ,លោក ចាន់ អាត ,លោកស្ងួស ជឿន សងប្រាក់៨២០.០០០ រៀល និងការប្រាក់៥% ក្នុង១ឆ្នាំ គិតពីថ្ងៃទី០៩-៧-១៩៩២ រហូតដល់ថ្ងៃសងគ្រប់ទៅចុងចម្លើយ។

៤-រឹបអូសប្រាក់ប្រដាប់ក្តី ចំនួន១៩.០០០៛ ដែលលោកហួត វ៉ាន់ហាន បានបង់គឺ :

-ពន្ធចុះបញ្ជីក្តី និង ពន្ធហ្លឹងចំនួន៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០៛ សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ;

-ចំណាយលើការប្រគល់ដីកាកោះចំនួន ១៥.០០០៛ សរុប ១៩.០០០៛ .

ហើយតំរូវឱ្យដើមចោទសងប្រាក់ ១៩.០០០៛ នេះទៅចុងចម្លើយវិញ ។

បង្គាប់ឱ្យដើមចោទបង់ពន្ធសមាមាត្រ១% លើប្រាក់ដែលត្រូវសងទៅចុងចម្លើយ ។

៥-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី០៩ខែកក្កដា ឆ្នាំ២០០៤ ។